# សេចក្តីប្រកាសព័ត៌មាន
# កម្មវិធីសម្ពោធជាផ្លូវការនៃ Cambodia Futures Lab

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ ២០២១ - កាលពីថ្ងៃទី ០៦ និង ០៧ ខែធ្នូ កន្លងទៅនេះ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទា និងអង្គការសហប្រជាជាតិប្រចាំកម្ពុជា បានសម្ពោធ និងដំណើរការ កម្មវិធី Cambodia Futures Lab ក្រោមកិច្ចសហការជាមួយ ក្រសួងមុខងារសាធារណៈ សាលាភូមិន្ទរដ្ឋបាល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហគ្រិនខ្មែរ ក្រសួងពាណិជ្ជកម្ម ក្រុមប្រឹក្សាជាតិគាំពារសង្គម ក្នុងកិច្ចសហការជាមួយវិទ្យាស្ថាន MIT/Presencing និង មូលនិធិ United in Diversity Foundation នៃប្រទេសឥណ្ឌូណេស៊ី។

កម្មវិធី Cambodia Futures Lab កំពុងចាប់ផ្តើមដំណើរការនូវគំនិតផ្តួចផ្តើមសិក្សាដែលមានរយៈពេល ៦ ខែ ដើម្បីរួមគ្នាបង្កើតមាគ៌ាក្នុងការសម្រេចបាននូវវិបុលភាព បរិយាប័ន្ន និងនវានុវត្តន៍ និងដើម្បីកៀរគរភាគីពាក់ព័ន្ធនានា មកពីរដ្ឋាភិបាល វិស័យឯកជន សង្គមស៊ីវិល និងអង្គការសហប្រជាជាតិ ក្នុងការគិតគូរសារជាថ្មីឡើងវិញអំពីរបៀបដែលបញ្ហាអន្តរវិស័យ ដូចជាកិច្ចគាំពារសង្គម ការប្រែប្រួលអាកាសធាតុ និងការផ្លាស់ប្តូរផ្នែកឌីជីថល អាចត្រូវបានយកមកពិចារណានៅក្នុងដំណោះស្រាយនៅកម្រិតគោលនយោបាយ។

តើភាគីពាក់ព័ន្ធនានាអាចគិតគូរឡើងវិញ ពីអនាគតដែលកាន់តែប្រកបដោយនិរន្តរភាពដោយរបៀបណា? តើភាពជាអ្នកដឹកនាំ នវានុវត្តន៍ និងការសិក្សាការរៀនសូត្រអាចជួយកែប្រែមាគ៌ាអភិវឌ្ឍន៍របស់ប្រទេសកម្ពុជា ដើម្បីសម្រេចបាននូវរបៀបវារៈឆ្នាំ ២០៣០ សម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាពយ៉ាងដូចម្តេច?

«ដើម្បីធានាថាគោលនយោបាយរបស់យើងអាចឈានដល់វិសាលភាពអតិបរិមា និងដល់ប្រជាជនដែលខ្វះខាតបំផុត ការឆ្លើយតបរបស់យើងគួរតែត្រូវបានតាក់តែងរៀបចំ និងចូលរួមជំរុញដោយរដ្ឋាភិបាល អាជីវកម្ម សង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍។ ជំហានដំបូងរបស់យើងគឺផ្តោតលើ កម្មវិធី Cambodia Futures Lab ដើម្បីលើកកម្ពស់ការធ្វើសមាហរណកម្មគោលនយោបាយ ជាពិសេសក្នុងកិច្ចគាំពារសង្គម និងធានាថាគ្មាននរណាម្នាក់ត្រូវបានទុកចោល» ប្រសាសន៍ ឯកឧត្តម សំហេង បុរស រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

«យើងប្តេជ្ញាចំពោះពហុភាគីនិយមក្នុងសតវត្សទី ២១ ដែលអង្គការសហប្រជាជាតិអាចបង្កើតនូវវេទិកា ដូចជា Cambodia Futures Lab នេះ ដើម្បីជួយសម្រួលដល់កិច្ចសហប្រតិបត្តិការអន្តរវិស័យលើកកម្ពស់នវានុវត្តន៍ និងបង្កើតដំណោះស្រាយចាំបាច់ ដើម្បីពន្លឿនការសម្រេចបាននូវរបៀបវារៈឆ្នាំ ២០៣០ សម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព» ប្រសាសន៍របស់លោកស្រី Pauline Tamesis ប្រធានអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា។

ក្នុងសុន្ទរកថាបើកនៃកម្មវិធិសម្ពោធនេះ ក៏មាននូវបទបង្ហាញរបស់ លោកសាស្ត្រាចារ្យ Otto Scharmer នៃវិទ្យាស្ថាន MIT/Presencing ដែលជាអ្នកនិពន្ធ «ទ្រឹស្តី U៖ ការដឹកនាំពីអនាគតគឺវេលាដែលត្រូវងើបឡើង ឬ Leading from the Future as it Emerges» ជាទ្រឹស្តីដែលត្រូវបានគេស្គាល់ថាដើម្បីពណ៌នាជុំវិញការផ្លាស់ប្តូរផ្នត់គំនិតជាមូលដ្ឋានពី បុគ្គលនិយម ទៅជា ពហុនិយម ឬ ego ទៅ eco និង ស្ថាប័នដែលធ្វើការតែឯង ទៅជាស្ថាប័នដែលធ្វើការជាបណ្តាញ ដើម្បីដោះស្រាយបញ្ហាប្រឈមដ៏ស្មុគស្មាញនៃការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព។ អ្នកចូលរួមក្នុងកម្មវិធីសម្ពោធនេះ បានពិភាក្សាអំពីធាតុចូលសំខាន់ៗនៃការគិតជាប្រព័ន្ធ និងការបង្កើតនូវចេតនារួម ដែលជាមូលដ្ឋានគ្រឹះសម្រាប់ជំរុញការអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជា។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖

១. កញ្ញា កែវ ស្រីស្រស់ មន្ត្រីទំនាក់ទំនង នៃការិយាល័យប្រធានអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា
ទូរស័ព្ទ៖ +855 11 88 57 66, អ៊ីមែល៖ sreysros.keo@un.org

២. លោក ឈួរ សុបញ្ញា ប្រធានលេខាធិការដ្ឋាន នៃអនុគណៈកម្មាធិការជំនួយសង្គម នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទា
ទូរស័ព្ទ៖ +855 12 53 81 18, អ៊ីមែល៖ chhoursopannha@yahoo.com